ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត បាត់ដំបង

ស្រុក បាណន

ឃុំ ឈើទាល

ឈើទាលថ្ងៃទី១៤...ខែឧសភាឆ្នាំ ២០១០

លេខ ០១១ /ឃ.ឈ.ទ
២០១០

# សេចក្តីជូនដំណឹង

## មេឃុំ ឈើទាល

សូមគោរពជម្រាបជូនដំណឹងបងប្អូនប្រជាពលរដ្ឋ ក្នុងឃុំឈើទាលទាំងអស់ឱ្យបានជ្រាបថា : ដោយយោងលើស្មារតី ដែលរៀបចំឡើងដោយគណកម្មការទទួលបន្ទុក គ្រប់គ្រងគ្រឿងស្រវឹង នៅសាលាឃុំឈើទាល ស្តីពី ការទប់ស្កាត់ការប្រើប្រាស់គ្រឿងស្រវឹងនាថ្ងៃទី ៣០ខែមេសាឆ្នាំ ២០១០ ដូច្នេះក្នុងនាមខ្ញុំ ជាប្រធានក្រុមប្រឹក្សាឃុំឈើទាល សូមជូនដំណឹងដូចខាងក្រោម :

១.មិនអនុញ្ញាតឱ្យជនណាម្នាក់ ទទួលទានគ្រឿងស្រវឹងគ្រប់ប្រភេទនៅក្នុងទីវត្ត អារាមសាលារៀន មណ្ឌលសុខភាព ។

២.មិនអនុញ្ញាតឱ្យជនណាម្នាក់ លើកប៉ាណូផ្សព្វផ្សាយពាណិជ្ជកម្មលក់គ្រឿងស្រវឹងគ្រប់ប្រភេទនៅក្នុងឃុំ ចម្ងាយពីវត្ត ឬសាលារៀន៣០០ម៉ែត្រ ។

៣.ហាមលក់គ្រឿងស្រវឹងគ្រប់ប្រភេទ ឱ្យក្មេងក្រោមអាយុ ១៦ ឆ្នាំ ។

៤. អ្នកផឹកគ្រឿងស្រវឹង ក្នុងឃុំកុំឱ្យហួសពេលវេលា កំណត់ម៉ោង ១០ យប់ ។

៥.អ្នកផឹកគ្រឿងស្រវឹង ក្នុងឃុំទាំងឡាយ ឱ្យចេះគោរពច្បាប់ចរាចរផ្លូវគោក ម្យ៉ាងវិញទៀតដោយយល់ឃើញថា កុមារក្រោមអាយុ ១៨ ឆ្នាំ ជាសសរទ្រូង របស់ប្រទេសជាតិយើង ។

- សូមកុំបង្ខំ កុមារក្រោមអាយុ ១៨ ឆ្នាំ ឱ្យទៅទិញស្រា ឬ ហូបគ្រឿងស្រវឹង និងអ្នកលក់ស្រា គួរកុំលក់ស្រាឱ្យអ្នកទិញណាដែលមានអាយុក្រោម ១៦ ឆ្នាំ ។

ទទួលបានសេចក្តីជូនដំណឹងនេះ សូមលោក លោកស្រី និង ប្រជាពលរដ្ឋក្នុងឃុំឈើទាលជ្រាបជាព័ត៌មាន ។

មេឃុំ

ម៉ែន យឿន